# បរិយាយបណ្ណឱសថ
# ហ្វាហ្វូឡិច ព្យួរតាមសរសៃឈាម

## FARFOLEX

Solution for Infusion
Ofloxacin 200mg

**I រូបភាពឱសថ** :

-ជាឱសថប្រភេទសូលុយស្យុងសំរាប់ចាក់ព្យួរតាមសរសៃឈាម

-១ប្រអប់មាន ១ដបប្លាស្ទិក ចំណុះ 100ml

**II សមាសធាតុផ្សំ** : ក្នុង 100ml មាន៖

-Ofloxacin……………………..200mg

**III គុណភាពព្យាបាល** :

ជាប្រភេទឱសថអង់ទីប៊ីយ៉ូទិកបិតក្នុងក្រុម quinolone ប្រើសំរាប់ព្យាបាលជំងឺឆ្លងច្រើនប្រភេទដែលកបនឹងឱសថនេះដូចជា៖

-ជំងឺឆ្លងក្នុងផ្លូវដង្ហើម ដូចជា៖

  - ជំងឺរលាកសួត
  - ជំងឺរលាកទងសួតស្រួចស្រាវនិងរ៉ាំរ៉ៃ

-ជំងឺឆ្លងក្នុងផ្លូវដង្ហើមផ្នែកខាងលើស្រួចស្រាវនិងរ៉ាំរ៉ៃ (លើកលែងតែជំងឺរលាកអាមីដាលស្រួចស្រាវ)

-ជំងឺឆ្លងលើស្បែកនិងជាលិកាទន់

-ជំងឺឆ្លងក្នុងឆ្អឹងនិងសន្លាក់

-ជំងឺឆ្លងផ្ទៃខាងក្នុងពោះ

-ជំងឺឆ្លងក្នុងផ្លូវក្រពះពោះវៀន

-ជំងឺឆ្លងនិងរលាកឆ្អឹងត្រគាក

-ជំងឺឆ្លងនិងរលាកផ្លូវបន្តពូជនិងផ្លូវបង្ហូរនោមកំរិតស្រាលនិងធ្ងន់ធ្ងរ

-ជំងឺប្រម៉េះមាត់ស្បូន និងប្រម៉េះទឹកបាយដោយសារមេរោគហ្គូណូកូក

-ជំងឺរលាកក្រពេញប្រូស្តាត

-ជំងឺមេរោគរីកសាយភាយក្នុងឈាម

-បង្ការជំងឺឆ្លងដោយបាក់តេរីចំពោះអ្នកជំងឺដែលមានប្រព័ន្ធការពាររាង្គកាយចុះខ្សោយ(ដូចជាករណីមានការកើនឡើងចំនួន neutrophils ចំពោះអ្នកជំងឺគ្រុនក្តៅដែលសង្ស័យថាមានជំងឺឆ្លង)

**IV ការហាមប្រើ** :

ឱសថនេះហាមប្រើចំពោះលក្ខខណ្ឌដូចខាងក្រោម៖

-ចំពោះអ្នកងាយមានប្រតិកម្មជាមួយនឹង ofloxacin ឬជាមួយឱសថផ្សេងទៀតក្នុងក្រុម fluoroquinolone ឬជាមួយសារធាតុផ្សំណាមួយនៃឱសថនេះ។

-ចំពោះអ្នកជំងឺកូនក្មេងអាយុក្រោម១៨ឆ្នាំ

-ចំពោះស្ត្រីមានផ្ទៃពោះ

-ចំពោះស្ត្រីបំបៅដោះកូន

-ចំពោះអ្នកជំងឺដែលថយចុះកំរិតអង់ហ្ស៊ីម glucose-6-phosphate dehydrogenase

-ចំពោះអ្នកជំងឺឆ្កួតជ្រូក

-ចំពោះអ្នកមានជំងឺរលាកសរសៃពួរសាច់ដុំដោយសារការប្រើឱសថក្នុងក្រុម fluoroquinolone កន្លងមក

**V ការប្រុងប្រយ័ត្ន** :

ឱសថនេះត្រូវប្រុងប្រយ័ត្នចំពោះលក្ខខណ្ឌដូចខាងក្រោម៖

-ចំពោះអ្នកជំងឺឆ្កួតជ្រូក ឬអ្នកធ្លាប់មានប្រវត្តិកើតជំងឺប្រព័ន្ធសរសៃប្រសាទកណ្តាល

-ចំពោះអ្នកជំងឺធ្លាប់មានប្រវត្តិកើតជំងឺខ្សោយសាច់ដុំ

-ចំពោះអ្នកជំងឺខ្សោយមុខងារថ្លើម ឬមុខងារតំរងនោម

-ចំពោះកូនក្មេងនិងមនុស្សវ័យជំទង

-ចំពោះមនុស្សចាស់

-ក្នុងអំឡុងពេលឬក្រោយការព្យាបាលដោយប្រើឱសថនេះអាចធ្វើឲ្យរាកដោយសារតែមានរលាកភ្នាសពោះវៀន។ ដូច្នេះត្រូវបញ្ឈប់ការប្រើឱសថនេះភ្លាមៗ ប្រសិនបើអាការៈរាករបស់អ្នកជំងឺមានសភាពធ្ងន់ធ្ងរ។

-ឱសថនេះមិនត្រូវបានណែនាំឲ្យប្រើជាទូទៅចំពោះកូនក្មេង និងមនុស្សវ័យជំទង់ លើកលែងតែមានផលចំណេញច្រើន ជាងហានិភ័យ។

-ចំពោះអ្នកជំងឺដែលព្យាបាលដោយប្រើឱសថនេះ អាចធ្វើឲ្យប៉ះពាល់ដល់លទ្ធផលវិជ្ជមានក្នុងការវិភាគរកសារធាតុញៀនក្នុងទឹកនោម

-ចំពោះអ្នកជំងឺដែលព្យាបាលដោយប្រើឱសថនេះត្រូវជៀសវាងប៉ះពាល់ផ្ទាល់ជាមួយពន្លឺព្រះអាទិត្យ ឬកាំរស្មី UV

-ចំពោះអ្នកមានជំងឺតំណពូជដោយកំរនៃភាពមិនធន់ជាមួយនឹងសារធាតុកាឡាក់តូស

-ឱសថនេះអាចធ្វើឲ្យប៉ះពាល់ដល់សមត្ថភាពបើកបរនិងការបញ្ជាគ្រឿងម៉ាស៊ីន

-មិនត្រូវប្រើឱសថនេះលើសកំរិតណែនាំ

-មិនត្រូវប្រើឱសថនេះហួសកាលបរិច្ឆេទប្រើប្រាស់

-មិនត្រូវប្រើឱសថនេះទេ ប្រសិនបើសូលុយស្យុងក្នុងដបឡើងល្អក់ ឬដបធ្លាយ

**VI ផលរំខាន** :

ផលរំខានដែលកើតមានមិនសូវញឹកញាប់របស់ឱសថនេះរួមមាន៖

-ជំងឺឆ្លងនិងការរាតត្បាតជំងឺឆ្លង៖ ជំងឺផ្សិត

-វិបត្តិគ្រាប់ឈាមនិងប្រព័ន្ធផលិតគ្រាប់ឈាម៖ កើនឡើងចំនួន eosinophils

-វិបត្តិប្រព័ន្ធភាពស៊ាំសរីរាង្គ៖ ប្រតិកម្មអាណាហ្វីឡាក់ទិក

-វិបត្តិអាហារូបត្ថម្ភនិងមេតាបូលីស៖ មិនសូវឃ្លាន

-វិបត្តិផ្លូវចិត្ត៖ រវើរវាយ គេងមិនលក់

-វិបត្តិប្រព័ន្ធសរសៃប្រសាទ៖ ឈឺក្បាល ធីងធោង គេងមិនលក់ មិនសូវដឹងរសជាតិ

-វិបត្តិចក្ខុ៖ ស្រវាំងភ្នែក រមាស់ភ្នែក

-វិបត្តិត្រចៀកនិងបំពង់សំលេង៖ ហឹងត្រចៀក វិលមុខ

-វិបត្តិបេះដូង៖ បេះដូងដើរញាប់

-វិបត្តិសរសៃឈាម៖ រលាកសរសៃឈាម

-វិបត្តិផ្លូវដង្ហើម៖ ពិបាកដកដង្ហើម

-វិបត្តិក្រពះពោះវៀន៖ ក្អួត ចង្អោរ រាក ហើមពោះ ពិបាករំលាយអាហារ

-វិបត្តិស្បែកនិងជាលិកាទន់៖ ឡើងកន្ទួលរមាស់ ក្រហមស្បែក កន្ទាលត្រអាក

-វិបត្តិថ្លើមនិងប្រម៉ាត់៖ កើនឡើងអង់ហ្ស៊ីមក្នុងថ្លើម កើនឡើងកំរិតប៊ីលីរុយប៊ីនក្នុងថ្លើម

-វិបត្តិឆ្អឹងសាច់ដុំ៖ ឈឺឆ្អឹងសាច់ដុំ ឈឺសន្លាក់ រលាកសរសៃពួរសាច់ដុំ

-វិបត្តិតំរងនោម៖ កើនឡើងកំរិត creatinine ក្នុងឈាម

-វិបត្តិទូទៅនិងលើកន្លែងប្រើ៖ អស់កម្លាំង ក្តៅខ្លួន ឈឺលើកន្លែងប្រើ

➢ **ត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យ ប្រសិនបើមានប្រតិកម្មរំខានណាមួយកើតឡើង។**

**VII អន្តរកម្មឱសថ** :

គួរជៀសវាងប្រើរួមផ្សំគ្នាជាមួយឱសថដូចខាងក្រោម៖

-Antiarrythmics, Tricyclic antidepressants, Macrolides, Antipsychotics

-Anticoagulants

-Theophylline, Fenbufen or NSAIDs

-Glibenclamid

-Probenecid, Cimetidine, Furosemide, Methotrexate

-Vitamin K antagonists

**VIII ការរក្សាទុក** :

-ត្រូវរក្សាទុកនៅសីតុណ្ហភាពក្រោម 30ºC

-ត្រូវទុកកុំឲ្យត្រូវកំដៅថ្ងៃ និងសំណើម

-ត្រូវទុកឲ្យផុតពីដៃកូនក្មេង

**IX កំរិត និងរបៀបប្រើ** :

❖ **កំរិតប្រើ៖**

-កំរិតប្រើឱសថនេះគឺអាស្រ័យទៅតាមប្រភេទនិងសភាពធ្ងន់ធ្ងររបស់ជំងឺឆ្លង។ កំរិតប្រើប្រចាំថ្ងៃរបស់ឱសថនេះអាចប្រើរហូតដល់ 400mg ប្រើតែ១ដងគត់ ក្នុង១ថ្ងៃ។ ក្នុងករណីប្រើបែបនេះ ជាការល្អប្រសើ ឱសថនេះគួរប្រើនៅពេលព្រឹក។

-កាលណាកំរិតប្រើប្រចាំថ្ងៃលើសពី 400mg ត្រូវប្រើចែកជា២ដង ក្នុងចន្លោះពេលស្មើរគ្នា ក្នុងថ្ងៃ។

**ចំពោះមនុស្សពេញវ័យ៖** កំរិតប្រើធម្មតាតាមសរសៃឈាមចំពោះមនុស្សពេញវ័យមានដូចខាងក្រោម៖

-សំរាប់ព្យាបាលជំងឺឆ្លងក្នុងផ្លូវបង្ហូរនោមកំរិតស្រាលនិងកំរិតធ្ងន់៖ កំរិតណែនាំឲ្យប្រើគឺ 200mg ក្នុង១ថ្ងៃ។

-សំរាប់ព្យាបាលជំងឺឆ្លងក្នុងផ្លូវដង្ហើម៖ កំរិតណែនាំឲ្យប្រើគឺ 200mg ប្រើ២ដង ក្នុង១ថ្ងៃ។

-សំរាប់ព្យាបាលជំងឺមេរោគសាយភាយក្នុងឈាម៖ កំរិតណែនាំឲ្យប្រើគឺ 200mg ប្រើ២ដង ក្នុង១ថ្ងៃ។

-ជំងឺឆ្លងលើស្បែកនិងជាលិកាទន់៖ កំរិតប្រើគឺ 400mg ប្រើ២ដង ក្នុង១ថ្ងៃ។

**ចំពោះកូនក្មេង និងមនុស្សវ័យជំទង់៖**

-ឱសថនេះមិនណែនាំឲ្យប្រើចំពោះកូនក្មេងនិងមនុស្សវ័យជំទង់កំពុងលូតលាស់ទេ។

**ចំពោះមនុស្សចាស់៖** កំរិតប្រើគឺអាស្រ័យទៅតាមប្រភេទជំងឺឆ្លងនិងកំរិត creatinine របស់អ្នកជំងឺ។

ចំពោះអ្នកជំងឺខ្សោយមុខងារតំរងនោម៖ កំរិតប្រើឱសថនេះគឺអាស្រ័យទៅតាមកំរិត creatinine ក្នុងឈាមរបស់អ្នកជំងឺដូចខាងក្រោម៖

-កាលណាកំរិត creatinine នៅចន្លោះពី 50ml/min ទៅ 20ml/min៖ កំរិតប្រើគឺ 100mg ទៅ 200mg រៀងរាល់២៤ម៉ោងម្តង

-កាលណាកំរិត creatinine តូចជាង 20ml/min៖ កំរិតប្រើគឺ 100mg រៀងរាល់២៤ម៉ោងម្តង

-ករណីលាងឈាម៖ កំរិតប្រើគឺ 200mg រៀងរាល់៤៨ម៉ោងម្តង

**ចំពោះអ្នកជំងឺខ្សោយមុខងារថ្លើម៖**

-កំរិតណែនាំឲ្យប្រើគឺមិនត្រូវប្រើលើសពី 400mg ក្នុង១ថ្ងៃទេ។

❖ **ការណែនាំពីរបៀបប្រើ៖**

-ឱសថនេះប្រើចាក់ព្យួរតាមសរសៃឈាមតែប៉ុណ្ណោះ។

-ត្រូវបង្ហូរថ្នាំនេះយឺតៗតាមសរសៃវ៉ែនធំដើម្បីជៀសវាងការរលាកសរសៃឈាម។

❖ **រយៈពេលព្យាបាល៖**

-រយៈពេលព្យាបាលគឺអាស្រ័យទៅតាមការឆ្លើយតបរបស់មេរោគឆ្លងនៃជំងឺ

-ដូចជាឱសថអង់ទីប៊ីយូទិកផ្សេងទៀតដែរ ការព្យាបាលដោយប្រើឱសថនេះត្រូវបន្តប្រើរយៈពេល៣ថ្ងៃបន្ថែមទៀតក្រោយពេល បាត់រោគសញ្ញាជំងឺ។

-ក្នុងករណីភាគច្រើននៃជំងឺឆ្លងស្រួចស្រាវ រយៈពេលព្យាបាលដោយប្រើឱសថនេះគឺមានរយៈពេលពី៧ទៅ១០ថ្ងៃ។ នៅពេល ដែលរោគសញ្ញាជំងឺបានធូរស្រាលហើយ អ្នកជំងឺត្រូវប្តូរថ្នាំនេះពីការចាក់តាមសរសៃឈាមមកប្រើប្រភេទថ្នាំគ្រាប់លេបតាមមាត់វិញ។

-ការព្យាបាលដោយប្រើឱសថនេះគឺមិនត្រូវលើសពីរយៈពេល២ខែទេ។

➢ **មុននឹងប្រើឱសថនេះ ត្រូវពិគ្រោះជាមួយគ្រូពេទ្យ។**

**X លេខបញ្ជិកា**: CAM N0153IP-17

**XI ផលិតដោយ**: Abaris Healthcare Pvt. Ltd. (India)


បានបកប្រែនិងត្រួតពិនិត្យដោយនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង។

លេខ :១៧៤៦/១៧ ឱអបស ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៧